សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ :៩៥៣
ចុះថ្ងៃទី០១/១០/២០១២

សាលដីកា
លេខ : ៨២ "ក្រ IV ច"
ចុះថ្ងៃទី ១៨/១២/២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ: ០៦ក្រ ចុះថ្ងៃទី ០៨.០២.១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ នាថ្ងៃទី១៨/១២/២០១៣ ដោយមាន ៖

### សមាសភាពក្រុមប្រឹក្សា

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រុមប្រឹក្សា

### តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

### ក្រឡាបញ្ជី

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ : ៩៥៣ ចុះថ្ងៃទី០១/១០/២០១២ រវាង៖

-ជនជាប់ចោទឈ្មោះ [redacted]សំរិទ្ធ ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ មុខរបរយោធា ទីកន្លែងកំណើតចាក់អង្រែក្រោម រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នផ្ទះ[redacted]សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted]មានកូន ០១ នាក់ ទោសពីមុន គ្មាន ។ (ដើមបណ្តឹងឧទ្ធរណ៍)

-ឃាត់ខ្លួននៅថ្ងៃទី២៤-០១-២០១២ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៣១ តព្រ ចុះថ្ងៃទី ២៦-០១-២០១២ ដីកាបង្គាប់ឱ្យដោះលែងនៅក្រៅឃុំលេខ ៩១៨ តព្រ ចុះថ្ងៃទី២៩-៣-២០១២។

មេធាវីការពារសិទ្ធិ លោក [redacted]សុទ្ធី ។ ៧៧៥

ជាប់ចោទពីបទ : ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ ប្រព្រឹត្តនៅចំណុចដីឡូត៍លេខ១៥០៣ ផ្លូវជាតិលេខ២ ភូមិទួលរកា ក្រុមទី២០ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២ បទល្មើសមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]សុខរឿន ភេទប្រុស អាយុ ៤៩ឆ្នាំ ជាតិខ្មែរ មុខរបរ លក់បង្អែម ទីកន្លែងកំណើតភូមិដីឡូត៍លេខ ១៥០៣ ផ្លូវជាតិលេខ២ ភូមិទួលរកា ក្រុមទី២០ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃផ្ទះ១៥០៣ ផ្លូវជាតិលេខ ២ ភូមិទួលរកា ក្រុមទី២០ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

## ឯរឿងហេតុមានដូចតទៅ ៖

កាលពីថ្ងៃទី២៣-០១-២០១២ វេលាម៉ោង ១៤ និង ៣០នាទី ឈ្មោះ[redacted]សុភាព ភេទស្រី អាយុ ៣០ឆ្នាំ កំពុងតែអង្គុយលេង នៅដីឡូត៍លេខ ១៥០៣ ផ្លូវជាតិលេខ ២ ភូមិទួលរកា ក្រុមទី២០ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ស្រាប់តែឈ្មោះ [redacted] ដាណា ភេទស្រី អាយុ ២៤ឆ្នាំ មករករឿងឈ្លោះប្រកែកពីរឿងព្រំដី ខណៈនោះជនរងគ្រោះឈ្មោះ[redacted]សុខរឿន ភេទស្រី អាយុ ៤៩ឆ្នាំ បានចេញមកមើលព្រមជាមួយគ្នានោះឈ្មោះ [redacted] ដាណា បានស្រែកហៅជនត្រូវចោទឈ្មោះ[redacted] សំរិទ្ធ ភេទប្រុស អាយុ ២៩ឆ្នាំ ដែលត្រូវជាបងប្រុសរបស់ខ្លួន ឱ្យមកជួយខណៈនោះជនត្រូវចោទឈ្មោះ [redacted] សំរិទ្ធ មកដល់ក៏ទាញដុំឥដ្ឋប្រហោងគប់មកលើជនរងគ្រោះឈ្មោះ [redacted]សុខរឿន ចំបាតដៃខាងឆ្វេងបណ្តាលឱ្យមានរបួសហូរឈាម ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ: ៦២ "ខ" ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១២ ដែលមានខ្លឹមសារដូចខាងក្រោម ៖

១-ផ្តន្ទាទោសលើឈ្មោះ[redacted] សំរិទ្ធ ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ឆ្នាំ (ពីរឆ្នាំ) និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០ រៀល (បួនលានរៀល) សំរាប់ដាក់ចូលថវិការដ្ឋ ។

ពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ ប្រព្រឹត្តនៅចំណុចដីឡូត៍លេខ១៥០៣ ផ្លូវជាតិលេខ២ ភូមិទួលរកា ក្រុមទី២០ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣-០១-២០១២ តាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] សំរិទ្ធ សងសំណងថ្លៃថ្នាំព្យាបាល និងសំណងជំងឺចិត្តចំនួន ១០លានរៀល (ដប់លានរៀល) ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]សុខរឿន ។ ការទាមទារលើសពីនេះត្រូវបដិសេធចោល ។

២៤៦

៣-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២១-៨-២០១២ ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សុខឿន និងមេធាវីកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សំរិទ្ធ និងមេធាវីការពារជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣១-៨-២០១២ ។ បើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**បានឃើញ** ពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សំរិទ្ធ ។

**បានឃើញ** របាយការណ៍រឿង របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី០៨/០១/២០១៣។

**បានឃើញ** សេចក្ដីសន្និដ្ឋាន របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចុះថ្ងៃទី៣០/០១/២០១៣។

**<u>នាពេលសវនាការ</u>**

- ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿងក្ដី

- ជនជាប់ចោទ ឈ្មោះ [redacted] សំរិទ្ធ (វត្តមាន) : ប្អូនខ្លួនជាអ្នកឈ្លោះ ខ្លួនមិនបានគប់គាត់ទេ ខ្លួនមិនបានដឹងថា គាត់ត្រូវអ្វីទេ។

- តំណាងមហាអយ្យការសន្និដ្ឋានថា : អង្គហេតុបណ្ដាលមកពីការឈ្លោះប្រកែក និងវាយគ្នាទៅវិញទៅមក ហើយមានការគប់ដោយដុំឥដ្ឋប្រហោង។ ជនរងគ្រោះមិនមានរបួសធ្ងន់ធ្ងរទេ។ ដូច្នេះ ក្រុមប្រឹក្សាគប្បីពិចារណាលើទណ្ឌកម្ម "គួរតែព្យួរ" ទើបសមរម្យ។

- លោកមេធាវី [redacted] សុទ្ធី បានសន្និដ្ឋានថា: សាក្សីដែលដាក់បន្ទុកលើកូនក្ដីខ្លួន គឺសុទ្ធតែសាច់ញាតិរបស់ជនរងគ្រោះ។ រឿងកើតនៅថ្ងៃទី២៣ តែធ្វើកោសល្យវិច័យនៅថ្ងៃទី៣០។ សុំក្រុមប្រឹក្សាពិចារណាទៅលើសាក្សី និងសំបុត្រកោសល្យវិច័យ ។ ដូច្នេះ សុំក្រុមប្រឹក្សាឱ្យកូនក្ដីខ្លួនបានរួចផុតពីបទចោទ។

- ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ
- ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>សំអាងហេតុ</u>**

**យល់ឃើញថា :**

១/ តាមពាក្យបណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] សំរិទ្ធ ចុះថ្ងៃទី១៧/០៩/២០១២ ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៦២ "ខ" ចុះថ្ងៃទី៣១/០៨/២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់សេចក្ដីសម្រេចទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន។ ២២៨

២/ ជនជាប់ចោទឈ្មោះ [redacted] សំរិទ្ធ បានឆ្លើយនាពេលសវនាការសាលាឧទ្ធរណ៍ថា “ខ្លួនមិនបានប្រព្រឹត្តអំពើហិង្សាដោយចេតនា កាលពីថ្ងៃទី២៣/០១/២០១២ ដូចការចោទប្រកាន់នោះទេ”។ ចម្លើយនេះមិនអាចឲ្យក្រុមប្រឹក្សាជឿបានទេ ដោយហេតុថា មានសាក្សីពីររូបឈ្មោះ[redacted] គឹមស្នួន និងឈ្មោះ [redacted] សុភាព ដែលបានបំភ្លឺនៅមុខចៅក្រមស៊ើបសួរ (ឯកសារ២៤/៩) ដោយបានបញ្ជាក់ប្រហាក់ប្រហែលគ្នាថា “ជនជាប់ចោទ [redacted] សំរិទ្ធ បានយកដុំឥដ្ឋគប់ទៅលើជនរងគ្រោះ ស្របពេលដែលជនរងគ្រោះបានដើរចេញពីផ្ទះ ដើម្បីធ្វើការសួរនាំពីរឿងដែល[redacted]ដាណា ជេរជៀលប្រមាថឈ្មោះ[redacted] សុភាព “។

ម្យ៉ាងទៀតដោយផ្អែកតាមវិញ្ញាបនប័ត្ររបស់មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញចុះថ្ងៃទី៣០/០១/២០១២ បានបញ្ជាក់ថា ជនរងគ្រោះមានរបួសស្នាម និងការឈឺចាប់ដែលបណ្តាលមកពីជម្លោះ (តាមការអះអាងរបស់សាម៉ីជន) ប៉ុន្តែស្នាមរបួស និងការឈឺចាប់អាចជាសះស្បើយក្រោយពេលព្យាបាល ប្រសិនបើគ្មានផលវិបាកកើតឡើងជាយថាហេតុ។

៣/ ក្រុមប្រឹក្សាយល់ឃើញថា ការវាយតប់នេះ គឺបង្កឡើងរវាងម្តាយមីង និងក្មួយ ហើយក៏ពុំបានបង្កព្យសនកម្មអ្វីធ្ងន់ធ្ងរដល់ជនរងគ្រោះដែរ។ សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញដែលសម្រេចផ្តន្ទាទោសលើជនជាប់ចោទ ប្រាក់ពិន័យ និងសំណងជម្ងឺចិត្ត មានលក្ខណៈធ្ងន់ធ្ងរពេក មិនសមាមាត្រនឹងព្យសនកម្មរបស់ជនរងគ្រោះ ដូច្នេះក្រុមប្រឹក្សាគប្បីពិចារណាពីស្ថាសម្រាលទោស ប្រាក់ពិន័យ និងសំណងជម្ងឺចិត្ត។

៤/ សាលក្រមព្រហ្មទណ្ឌលេខ ៦២ “ខ” របស់សាលាដំបូងរាជធានីភ្នំពេញដែលមានសម្រេចមក មានលក្ខណៈត្រឹមត្រូវ គប្បីតម្កល់ទុកជាបានការលើកលែងតែចំណុចទណ្ឌកម្ម ប្រាក់ពិន័យ និងសំណងជម្ងឺចិត្ត គប្បីកែប្រែតាមការយល់ឃើញខាងលើ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១/ ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ[redacted] សំរិទ្ធ ចុះថ្ងៃទី១៧/០៩/២០១២ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២/ តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦២ “ខ” ចុះថ្ងៃទី ៣១/០៨/២០១២ លើកលែងតែ :

- ចំណុចទី ១ នៃសេចក្តីសម្រេចត្រង់ “ផ្តន្ទាទោសលើឈ្មោះ [redacted] សំរិទ្ធ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ” ត្រូវកែប្រែមកជា “ផ្តន្ទាទោសលើឈ្មោះ តាំង សំរិទ្ធ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតា តាមមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ” វិញ ។

- និងត្រង់ “ការពិន័យជាប្រាក់ចំនួន ៤,០០០,០០០ (បួនលាន) រៀលសម្រាប់ដាក់ចូលថវិការដ្ឋ” ត្រូវលុបចោល ។

២២៨

សាលដីកានេះចូលជាស្ថាពរ មានអានុភាពអនុវត្តតែលើឈ្មោះ [redacted] មាន ក្រៅពីនោះ ពុំមានអានុភាពអនុវត្តឡើយ ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់ មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

.................................................................................................................

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៤
ក្រឡាបញ្ជី

[redacted]

- និងកែប្រែចំណុចចំណុចទី២ ត្រង់ "បង្គាប់ឲ្យជនជាប់ចោទឈ្មោះ តាំង សំរិទ្ធ សងសំណងថ្លៃថ្នាំព្យាបាល និងសំណងជម្ងឺចិត្តចំនួន ១០លានរៀល (ដប់លានរៀល)" ត្រូវកែប្រែមកជា "បង្គាប់ឲ្យជនជាប់ចោទឈ្មោះ **តាំង សំរិទ្ធ** សងសំណងថ្លៃថ្នាំព្យាបាល និងជម្ងឺចិត្តចំនួន ៥០០,០០០ (ហាសិបម៉ឺន)រៀល" វិញ ។

ចំណុចក្រៅពីនេះត្រូវរក្សាទុកជាបានការដដែល ។

សាលដីកានេះ ត្រូវបានជំនុំជម្រះ និងប្រកាសជាសាធារណៈថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

ទុកសិទ្ធិសាទុក្ខក្នុងកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា ចាន់ សុភា | ហត្ថលេខា តាំង ស៊ុនឡាយ , អ៊ុំ សារិទ្ធ | ហត្ថលេខា ចាយ ច័ន្ទតារាវណ្ណ |

---

ចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៤

ក្រឡាបញ្ជី

ចាន់ សុភា

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

យូ មុីនឡេង